## មេរៀនទី៩

# ប្រសិទ្ធភាពនៃការធ្វើការងារជាក្រុម



Mrs. Bun Sophany, Mr. Prak Pouv, Dr. Meoun Lina

# មាតិកា



1) ល្បែងសិក្សា
2) មើលវីដេអូ
3) ប្រសិទ្ធភាពនៃការធ្វើការងារជាក្រុម
4) និយមន័យ
5) ការអនុវត្តការងារជាក្រុមនៅក្នុងថ្នាក់រៀន
6) សារៈសំខាន់នៃប្រសិទ្ធភាពនៃការធ្វើការងារជាក្រុម

# វត្ថុបំណងមេរៀន



1) កំណត់បាននូវបញ្ញត្តិមូលដ្ឋានពីប្រសិទ្ធភាពនៃការធ្វើការងារជាក្រុម
2) ពិភាក្សាការងារជាលក្ខណៈក្រុម បំពេញតាមតួនាទី ដោយមានការទទួលខុសត្រូវលើកិច្ចការរបស់ខ្លួនបានច្បាស់លាស់
3) ផ្តល់គុណតម្លៃនិងសារៈប្រយោជន៍ដល់ក្រុមការងារ

# សំណួរលេងល្បែង

១ )សមត្ថភាពរបស់កុំព្យូទ័រត្រូវបានប្រើប្រាស់ក្នុងកម្មវិធីអស់ជាច្រើនឆ្នាំប៉ុន្តែឥឡូវនេះវាត្រូវបានគេយកទៅអនុវត្តន៍ទៅលើផលិតផល និងសេវាកម្មផ្សេងៗជាច្រើនទៀត នៅពេលដែលម៉ាស៊ីនមានសមត្ថភាពដូចមនុស្សដូចជាការសិក្សា ការវែកញែកហេតុផល និងការដោះស្រាយបញ្ហាគឺ៖

A. បញ្ញាសុប្បនិមិត្ត
B. កុំព្យូទ័រឆ្លាតវៃ
C. ម៉ាស៊ីនសិក្សា
D. Natural language

២) ការសិក្សានៃការបង្កើតក្បួនដោះស្រាយបែបកុំព្យូទ័រដោយស្វ័យប្រវត្តិតាមរយៈបទពិសោធន៍របស់កម្មវិធីមានលក្ខណៈទូលំទូលាយចាប់ពីកម្មវិធីទាញយកទិន្នន័យដែលរកឃើញក្នុងបរិមាណដ៏ច្រើននៃទិន្នន័យរហូតដល់ប្រព័ន្ធច្រោះ ព័ត៌មានដែលសិក្សាដោយស្វ័យប្រវត្តិពីចំណាប់អារម្មណ៍របស់អ្នកប្រើប្រាស់គឺ៖

A. បញ្ញាសុប្បនិមិត្ត
B. កុំព្យូទ័រឆ្លាតវៃ
C. ម៉ាស៊ីនសិក្សា
D. គ្មានចម្លើយត្រឹមត្រូវ

# សកម្មភាពមើលវីដេអូ



# សំណួរពិភាក្សា

1. តើអ្វីជាប្រសិទ្ធភាពនៃការធ្វើការជាក្រុម?
2. តើកត្តាសំខាន់ៗអ្វីខ្លះ ដែលរួមចំណែកដល់ក្រុមការងារឱ្យមានប្រសិទ្ធភាព ?
3. តើសមាសភាពក្រុមចម្រុះមានប្រយោជន៍យ៉ាងដូចម្តេចក្នុងការដោះស្រាយបញ្ហានិងការបង្កើតថ្មី ?
4. តើមានយុទ្ធសាស្រ្តអ្វីខ្លះ ដើម្បីធានាឱ្យមានការចូលរួមស្មើគ្នាពីសមាជិកក្រុមទាំងអស់ ?
5. តើត្រូវរៀបចំការអនុវត្តការងារជាក្រុមនៅក្នុងថ្នាក់រៀនដូចម្តេចដើម្បីឱ្យក្រុមទទួលបានជោគជ័យ ?

6. តើប្រសិទ្ធភាពការងារជាក្រុមមានសារៈសំខាន់អ្វីខ្លះ ?

## ១. តើអ្វីជាប្រសិទ្ធភាពនៃការធ្វើការជាក្រុម?

- ជាកិច្ចការដែលត្រូវធ្វើដោយក្រុមឱ្យទទួលបានភាពជោគជ័យ និងសេចក្ដីសម្រេចតាមគោលបំណងនីមួយៗ។
- ការងារជាក្រុម គឺជាវិធីសាស្រ្តមួយដ៏មានប្រសិទ្ធភាពក្នុងការជំរុញសកម្មភាពសិក្សា លើកទឹកចិត្ត អភិវឌ្ឍការគិតតាមបែបស៊ីជម្រៅការប្រាស្រ័យទាក់ទង និងហ៊ានក្នុងការធ្វើការសម្រេចចិត្តរបស់សិស្សានុសិស្សថែមទៀតផង។
- ការធ្វើការងារជាក្រុម គឺវិធីសាស្រ្តដ៏មានប្រសិទ្ធភាពបំផុតមួយក្នុងចំណោមវិធីសាស្រ្តទាំងឡាយ ដែលផ្ដល់សារៈសំខាន់ និងផលប្រយោជន៍ជាច្រើនដល់សិស្សានុសិស្សក្នុងការយកទៅអនុវត្តក្នុងថ្នាក់រៀនដើម្បីជួយពួកគាត់ឱ្យកាន់តែមានសមត្ថភាព ភាពប៉ិនប្រសព្វ និងមានទំនុកចិត្តលើខ្លួន។ សិស្សទទួលបាននូវបញ្ញត្តិមូលដ្ឋាន អំពីរបៀបក្នុងការសម្រប និងរស់នៅក្នុងសហគមន៍និងផ្សេងៗទៀតផង។

សរុបមក ការងារក្រុមគឺជាវិធីសាស្រ្តតម្រង់ទិសសិស្សានុសិស្សឱ្យទទួលបានភាពជោគជ័យនាថ្ងៃអនាគតទាំងក្នុងសាលានិងសង្គម។



# កិច្ចការក្រុមតម្រូវ



- ✓ ឲ្យសិស្សចែករំលែកចំណេះដឹងជាមួយមិត្តរួមថ្នាក់។
- ✓ ឲ្យសិស្សចេះធ្វើការងារជាក្រុម
- ✓ ឲ្យសិស្សមានការជឿជាក់លើខ្លួនឯង។
- ✓ សិស្សទទួលបានបញ្ញត្តិមូលដ្ឋាន អំពីរបៀបក្នុងការសម្រប និងរស់នៅក្នុងសហគមន និងផ្សេងៗទៀតផង។
- ✓ ការងារក្រុមជាវិធីសាស្រ្តតម្រង់ទិសសិស្សានុសិស្ស ឱ្យទទួលបានភាពជោគជ័យនាថ្ងៃអនាគតទាំងក្នុងសាលានិងសង្គម។
- ✓ លោក John Dewey « ថ្នាក់រៀនប្រជាធិបតេយ្យ»
- ✓ Einstein ទទួលបានកិត្តិយយ៉ាងខ្លាំងដោយការរកឃើញរឹទ្យាទីរិតេ ប៉ុន្តែបានពឹងផ្អែកលើការពិភាក្សាជាមួយនឹងមិត្ត ភក្តិគាត់ ព្រមទាំងសហសេវិករបស់គាត់ផងដែរ។



## ២. និយមន័យនៃពាក្យគន្លឹះ

- ប្រសិទ្ធភាពមានន័យថា បែបបទឬក៏លំនាំនៃការធ្វើឱ្យអ្វី មួយឱ្យបានសម្រេច។
- ការងារ មានន័យថាគឺជាកិច្ចដែលត្រូវធ្វើទៅតាមមុខងាររៀងខ្លួន តាមការចាត់តាំង និងប្រគល់ជូន ។
- ក្រុម គឺសំដៅដល់លំដាប់; ប៉ែកដោយតំណែង, ដោយមុខ, ដោយសង្កាត់, ដោយពួក។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ប្រសិទ្ធភាពការងារជាក្រុមគឺជាលំនាំឬបែបបទនៃការធ្វើការងារអ្វីមួយឱ្យបានជោគជ័យដោយក្រុម ឬពួក។



# ៣. ការអនុវត្តការងារជាក្រុមនៅក្នុងថ្នាក់រៀន

## ៣.១. ដំណើរការនៃរៀបចំក្រុមនីមួយៗ

- ដំណាក់កាលដំបូងនៃចាប់ផ្តើមការងារជាក្រុម។
-ត្រូវគិតអំពីភាពងាយស្រួលសម្រាប់ក្រុមដែលបានបង្កើតឡើង និងដើម្បីឱ្យពួកគេទទួលអារម្មណ៍ល្អ។
- ត្រូវតែគិតអំពីប្លង់ថ្នាក់រៀន និងចំនួនក្រុម។
-ត្រូវគិតផងដែរថាតើសិស្សម្នាក់អាចស្តាប់ឮសិស្សម្នាក់ទៀតបានច្បាស់ទេ ។



## ៣.២. ការរៀបចំសកម្មភាពក្រុមនីមួយៗ

១. តើគោលបំណងនៃ សកម្មភាពគឺជាអ្វី ?
២. តើគោលបំណងនោះនឹងត្រូវបន្តដោយឱ្យសិស្សធ្វើការងារក្រុមដោយរបៀបណា ?
៣. តើការងារពិតជាពិបាកដែលតម្រូវឱ្យសិស្សធ្វើការងារជាក្រុមឬទេ ?
៤. តើខ្លឹមសារមេរៀនេះ ទាមទារឱ្យធ្វើការងារជាក្រុមមែនឬទេ ?
៥. តើអ្នកមានហេតុផលបែបណាខ្លះ ដែលកិច្ចកាមិនត្រូវធ្វើការងារជាក្រុមនោះ?



## ៣.៣. ការណែនាំពីសកម្មភាពក្រុម

- ដាដំបូងអ្នកត្រូវប្រាប់ពីមូលហេតុនៃការធ្វើការងារជាក្រុម។
- ចូរភ្ជាប់សកម្មភាពទាំងនេះទៅខ្លឹមសារនៃមេរៀនសម្រាប់ថ្នាក់និងលទ្ធផលនៃការសិក្សារបស់សិស្ស។
- សិស្សត្រូវតែយល់ឱ្យបានច្បាស់ពីគោលបំណងនិងសារប្រយោជន៍ក្នុងការរៀនធ្វើការជាក្រុម។
- សូមឱ្យសិស្សបង្កើតជាក្រុមការងារឱ្យបានមុនពេលលោកគ្រូ អ្នកគ្រូផ្ដល់ការណែនាំដល់ពួកគេ។
- ចំពោះសកម្មភាពជាក្រុម មុនដំបូងត្រូវឱ្យសិស្សណែនាំខ្លួនម្នាក់ៗទៅក្នុងក្រុមពួកគេនិងផ្សេងៗ។
- បើការងារជាក្រុមមានរយៈពេលយូរគួរសម អ្នកអាចឱ្យពួកគេធ្វើសកម្មភាព និងបែងចែកក្រុមធំជាក្រុមតូចៗតទៀត ដើម្បីកសាងនូវខ្លឹមសារនៃប្រធានបទឱ្យបានកាន់តែល្អ។

TREY research

- ត្រូវពន្យល់រាល់កិច្ចការឱ្យបានច្បាស់លាស់ទៅកាន់ក្រុមនៅនីមួយៗជាពិសេសលទ្ធផលចុងក្រោយ។
- វិធីសាស្ត្រពន្យល់ណែនាំគឺអ្នកអាចធ្វើបានតាមរយៈការសរសេរអក្សរនៅលើក្តារខៀន និងរូបភាព។
- សកម្មភាពបន្ទាប់មកទៀត អ្នកអាចបង្កើតវិន័យសម្រាប់ក្រុមនីមួយៗ ព្រមទាំងវិសាលភាព ពេលវេលារបស់ក្រុមផងដែរ ។
- សូមអនុញ្ញាតិឱ្យសិស្សសួរសំណួរ ដើម្បីច្បាស់លាស់មុនពេលចាប់ផ្តើមកិច្ចការ។





# ៤. សារៈសំខាន់នៃប្រសិទ្ធភាពការងារជាក្រុម

## ៤.១. ការរៀនពីជំនាញសង្គមសំខាន់ៗ

- ជំនាញទំនាក់និងសង្គមសំខាន់ៗដូចជា ការធ្វើឱ្យមានភាពប្រសើរឡើងនៃសមត្ថភាពស្តាប់ និងប្រសិទ្ធភាពនៃការនិយាយស្តី។
- រៀនពីរបៀបនៃការស្តាប់អ្នកដឹកនាំក្រុមពួកគេនិងគ្រូបង្រៀន ។
- មានបទសោធន៍ទៅលើការរស់នៅក្នុងសង្គម។
- សិស្សក៏រៀនបន្ថែមទៀតពីរបៀបនៃការស្តាប់យោបល់របស់សមាជិកម្នាក់ទៅម្នាក់ ។
- ដឹងពីរបៀបនៃការផ្តល់តម្លៃ និងជឿជាក់លើសមត្ថភាពនិងយោបល់ពួកគេទៅក្នុងក្រុម និងរបៀបទំនាក់ទំនងជាមួយនឹងមនុស្សជុំវិញខ្លួន។



## ៤.២. ការកសាងទំនុកចិត្តលើខ្លួនឯង

- ការងារក្រុមបង្រៀនសិស្សឱ្យដឹងថា យោបល់ និងគំនិតរបស់ពួកគេត្រូវបានគោរព និងផ្តល់តម្លៃ។
- សិស្សកាន់តែសប្បាយនៅពេលដែលដឹងថា គ្រូជួយកសាងទំនុកចិត្តពួកគេ ព្រមទាំងនាំឱ្យការជួយជំរុញសកម្មភាពការងារជាក្រុមថ្ងៃក្រោយទៀតផងដែរ។
- ការរួមសកម្មភាពការងារជាក្រុម ជួយបង្ហាត់បង្រៀនសិស្សឱ្យមានជំនាញទំនាក់ទំនងកាន់តែប្រសើរ។
- សមាកជិកក្រុមទទួលអារម្មណ៍កក់ក្តៅ ហើយអាចក្លាយជាអ្នកចូលរួមយ៉ាងសកម្ម និងរៀនពីរបៀបរីករាយនឹងការងារជាក្រុម ។



## ៤.៣. កាត់បន្ថយភាពអាត្មានិយម

- ជាសក្តានុភាពរបស់វាក្នុងការកាត់បន្ថយភាពអត្មានិយមចំពោះការសិក្សាទៅលើសិស្សដទៃទៀត។
- បើសិនសិស្សក្លាយជាផ្នែកមួយនៃក្រុម ដែលត្រូវបានយកចិត្តទុកដាក់ពីសំណាក់សមាជិកក្រុម ជាកត្តាមួយដ៏សំខាន់ក្នុងការជួយប្រព័ន្ធគាំទ្រដ៏រឹងមាំថែមទៀត។
- សមាជិកក្រុមនឹងមានទំនោរគំនិតជាមួយគ្នា ព្រមទាំងអាចសហការគ្នា យ៉ាងមានប្រសិទ្ធភាព។
- សិស្សមានទំនុកចិត្តលើខ្លួនឯងពីសកម្មភាពជាក្រុមអាចផ្តល់អំណាចដល់សិស្សឱ្យក្រោកឈរឡើងសម្រាប់ជនរងគ្រោះផ្សេងទៀតក្នុងសហគមន៍របស់គេ ។



## ៣.៤. ជួយសិស្សឱ្យជោគជ័យនៅថ្ងៃអនាគត

- សារៈសំខាន់ និងសារប្រយោជន៍នៃការធ្វើការងារជាក្រុម ស្ទើរតែអាចបកប្រែទៅជាភាពជោគជ័យនៅក្នុងសង្គមក៏ថាបាន។
- ផ្លូវអាជីពតិចតួចណាស់ដែលសម្រេចភាគជោគជ័យដោយខ្លួនឯងបាននោះ។
- បុគ្គលិកក្រុមហ៊ុនមួយ ដំណើរទៅបានអាស្រ័យលើមនុស្សក្នុងក្រុមហ៊ុនសហការគ្នាទៅវិញទៅមកដើម្បីបំពេញភារកិច្ច។
- ការណែនាំសិស្សពីរបៀបធ្វើការងារជាក្រុម ជាការផ្តល់ឱកាសឱ្យពួកគេកាន់តែមានសមត្ថភាពនិងភាពរីករាយនៅពេលដែលបំពេញការងារ។
- សរុបមកការជោគជ័យរបស់ក្រុម ក៏ដូចជាការជោគជ័យសម្រាប់ខ្លួនឯងដែរ។



## ឧទាហរណ៍៖ ការបង្រៀនដោយប្រើវិធីសហការ និងបច្ចេកទេស Jigsaw

ជាបច្ចេកទេសពិភាក្សាមួយដែលនាំឱ្យអ្នកសិក្សាទទួលបាន ចំណេះដឹងតាមរយៈការចែករំលែកគំនិត ចេះសហការគ្នា បង្កើនការស្តាប់ ទំនាក់ទំនង និងបង្កើនជំនាញដោះស្រាយបញ្ហា ។ វាមានបីដំណាក់កាល៖

- **ទី១៖** បង្កើតក្រុមធម្មតាដោយមានអក្សរចំណាំផង (A,B,C,D..) ។
- **ទី២៖** បំបែកក្រុមទៅតាមជំនាញ (AនៅជាមួយA , B នៅជាមួយ B,…) គ្រូដាក់ប្រធានបទតាមក្រុមជំនាញ A,B,C ។
- **ទី៣៖** ចូលទៅក្រុមដើមវិញរួចចែករំលែកគំនិតដែលទទួលបានមកពីការពិភាក្សាជាមួយក្រុមតូច។ ចុងក្រោយធ្វើតេស្តវាយតម្លៃ ដែលមានទាំងតេស្តជាបុគ្គល និងជាក្រុម។ ក្រុមនេះ ត្រូវផ្លាស់ប្តូររៀងរាល់៥សប្តាហ៍ម្តងបន្ទាប់ពីសរុបពិន្ទុរកឃើញក្រុមជោគជ័យ។

តេស្តត្រូវផ្តោតលើជំនាញ២ គឺជំនាញទំនាក់ទំនង (សហការ) និងចំណេះដឹងដែលសិស្សបានពីការរៀន)

TREY research

# ជូនពរសំណាងល្អ

